ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ករណីឆបោករបស់ក្រុមហ៊ុន ស៊ី ជេ លេប័រ ស៊ឹបផ្លាយ

## ( CJ LABOUR SUPPLY CO.,LTD )

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា ក្រសួងមិនបានផ្តល់អាជ្ញាប័ណ្ណ និងអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី ជេ លេប័រ ស៊ឹបផ្លាយ(CJ LABOUR SUPPLY CO., LTD) ដែលមានទីស្នាក់ការ អគារលេខ១៣ ផ្លូវលេខ២៧១ ក្រុមទី៧ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរ ទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ព្រះរាជាណាចក្រថៃឡង់ដ៏ ប្រទេសគូវ៉ែត តំបន់រដ្ឋបាលពិសេសហុងកុង និងទៅធ្វើកម្មសិក្សាការីនៅប្រទេសជប៉ុននោះទេ។

ក្រុមហ៊ុន ស៊ី ជេ លេប័រ ស៊ឹបផ្លាយ(CJ LABOUR SUPPLY CO., LTD) បាននិងកំពុងឆបោកសាធារណជន ដោយបានក្លែងបន្លំប្រកាសអនុញ្ញាតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើជាទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ ដោយបានធ្វើការជ្រើសរើសពលករឱ្យទៅធ្វើការនៅតំបន់រដ្ឋបាលពិសេសហុងកុង។ ក្នុងករណីនេះ ក្រសួងបាននិងកំពុងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច រៀបចំសំណុំឯកសារប្តឹងទៅតុលាការ ដើម្បីចាត់វិធានការទៅតាមនីតិវិធីច្បាប់ជាធរមាន។

ក្រសួង សូមធ្វើការក្រើនរំលឹកដល់សាធារណជន ដែលមានបំណងទៅធ្វើការនៅក្រៅប្រទេសឱ្យមានការប្រុងប្រយ័ត្នខ្ពស់ មុនពេលសម្រេចចិត្តចុះឈ្មោះទៅធ្វើការតាមរយៈក្រុមហ៊ុនណាមួយ ត្រូវពិនិត្យលើបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់ដែលអនុញ្ញាតដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

សម្រាប់ព័ត៌មានបន្ថែម សូមមេត្តាទំនាក់ទំនងតាមទូរស័ព្ទលេខ ០២៣ ៨៨០ ៤៧៤ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬពិនិត្យមើលបញ្ជីឈ្មោះក្រុមហ៊ុន ដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ១២រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៨

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩